ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំស្តីពីការប្រើប្រាស់ ទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ



**ការវិនិយោគដើម្បីអភិវឌ្ឍន៍ដែលមិនបានគិតពី**
**ហានិភ័យគ្រោះមហន្តរាយនឹងនាំមកហានិភ័យកាន់តែច្រើន**

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤

# មាតិកា


**បុព្វកថា** ........ II

**សេចក្តីថ្លែងអំណរគុណ** ........ III

**អក្សរកាត់** ........ IV

**I. សារតារ** ........ 1

**II. គោលបំណងនៃការដាក់ឱ្យប្រើប្រាស់ទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ** ........ 3

**III. សេចក្តីណែនាំស្តីពីរបៀបធ្វើរបាយការណ៍ទិន្នន័យគ្រោះមហន្តរាយ** ........ 4

**ទម្រង់របាយការណ៍ទី១** - ការតាមដានត្រួតពិនិត្យព្រឹត្តិការណ៍មុនពេលគ្រោះមហន្តរាយ ........ 5

**ទម្រង់របាយការណ៍ទី២** - របាយការណ៍បន្ទាន់ ព្រឹត្តិការណ៍ក្នុងពេលគ្រោះមហន្តរាយ ........ 13

**ទម្រង់របាយការណ៍ទី៣** - របាយការណ៍បឋម ព្រឹត្តិការណ៍ក្នុងពេលគ្រោះមហន្តរាយ ........ 19

**ទម្រង់របាយការណ៍ទី៤** - បូកសរុបផលប៉ះពាល់និងខូចខាតថ្នាក់ស្រុក ........ 34

**ទម្រង់របាយការណ៍ទី៥** - បូកសរុបផលប៉ះពាល់និងខូចខាតថ្នាក់រាជធានី-ខេត្ត ........ 51

**ឧបសម្ព័ន្ធ ១** - រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី/ខេត្ត ........ 70

**ឧបសម្ព័ន្ធ ២** - រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក/ក្រុង/ខណ្ឌ ........ 73

**ឧបសម្ព័ន្ធ ៣** - រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ/សង្កាត់ ........ 76

**ឧបសម្ព័ន្ធ ៤** - លិខិតជូនដំណឹងស្តីពីការណែនាំអនុវត្តទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ ........ 78

# បុព្វកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងយោងតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបន្តពង្រឹងយន្តការឆ្លើយតបគ្រោះមហន្តរាយ ដោយផ្តោតលើការជួយគាំពារដល់ប្រជាជនរងគ្រោះទាំងក្នុងនិងក្រោយពេលមានគ្រោះមហន្តរាយ តាមរយៈការពង្រឹងស្ថាប័ន និងយន្តការពាក់ព័ន្ធ ពិសេសគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយបង្កើនថែមទៀត នូវកិច្ចសហការ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយតួអង្គពាក់ព័ន្ធជាអាទិ៍ កាកបាទក្រហមកម្ពុជា អង្គការមនុស្សធម៌អន្តរជាតិនានា វិស័យឯកជន សប្បុរសជន និងដៃគូផ្សេងទៀត ។ ក្នុងន័យនេះ ដោយមានការឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ( UNDP) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានរៀបចំបង្កើតទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ ដើម្បីធ្វើឱ្យការងារគ្រប់គ្រងគ្រោះមហន្តរាយកាន់តែប្រសើរឡើង ។

សៀវភៅណែនាំស្តីពីទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយនេះ មានគោលបំណងផ្តល់នូវចំណេះដឹងពីរបៀបធ្វើរបាយការណ៍នីមួយៗ ទៅតាមស្ថានការណ៍ជាក់ស្តែងទាំងមុនពេល ក្នុងពេលនិងក្រោយពេលគ្រោះមហន្តរាយកើតឡើង នៅថ្នាក់ក្រោមជាតិនិងមូលដ្ឋានសហគមន៍ ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការដាក់បញ្ចូលទិន្នន័យទៅក្នុងតារាង តាមរយៈទិន្នន័យនិងព័ត៌មានត្រឹមត្រូវច្បាស់លាស់នៅក្នុងរបាយការណ៍ ដែលមានការឯកភាពគ្នាជាមួយផ្នែកពាក់ព័ន្ធ ។ ម្យ៉ាងវិញទៀតទម្រង់របាយការណ៍នេះក៏អាចជួយថ្នាក់ដឹកនាំ គ្រប់លំដាប់ថ្នាក់ ធ្វើការវិភាគនិន្នាការគ្រោះមហន្តរាយនិងដាក់ចេញនូវវិធានការជាអាទិភាពឆ្លើយតបសង្គ្រោះបន្ទាន់ឱ្យមានប្រសិទ្ធភាព និងធ្វើការអំពាវនាវឬស្វែងរកការគាំទ្រជំនួយបាន ទាន់ពេលវេលា សម្រាប់ការកាត់បន្ថយបានការបាត់បង់ការខូចខាតនិងការឈឺចាប់របស់ប្រជាជនរងគ្រោះ ហើយនិងដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដើម្បីរក្សាទុកជាផលប្រយោជន៍ដល់សាធារណជនទូទៅ ដែលត្រូវការប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍សង្គមនៅពេលអនាគត ។

សៀវភៅណែនាំស្តីពីការដាក់ឱ្យប្រើប្រាស់ទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយនេះ ជាឧបករណ៍ដ៏មានអត្ថប្រយោជន៍ជួយដល់ថ្នាក់ដឹកនាំរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់មន្ទីរពាក់ព័ន្ធក្នុងការប្រមូលទិន្នន័យគ្រោះមហន្តរាយដើម្បីជួយពង្រឹងនូវកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព និងអាចទទួលបាននូវការគាំទ្រនូវតម្រូវការអាទិភាព ចាំបាច់ពីរាជរដ្ឋាភិបាល ម្ចាស់ជំនួយ សប្បុរសជននិងភ្នាក់ងារមនុស្សធម៌នានា ។

ខ្ញុំសង្ឃឹមថាទម្រង់របាយការណ៍នេះ នឹងត្រូវបានប្រើប្រាស់តាមការណែនាំនៅក្នុងសៀវភៅនេះ ពេលមានព្រឹត្តិការណ៍គ្រោះមហន្តរាយកើតឡើងនៅពេលអនាគត ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះការខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា និងក្រុមការងាររបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងUNDP ដែលបានចូលរួមសហការបង្កើតទម្រង់របាយការណ៍នេះឡើង ។

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**និងជា អនុប្រធានទី១ គ.ជ.គ.ម**

**បណ្ឌិត ញឹម វណ្ណដា**

# សេចក្តីថ្លែងអំណរគុណ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះស្ថាប័ននិងបុគ្គល ដែលបានរួមចំណែកក្នុងការរៀបចំសេចក្តីណែនាំប្រើប្រាស់ទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ ។ ក្នុងអំឡុងពេលរៀបចំទម្រង់របាយការណ៍ទិន្នន័យទាំងនេះសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនត្រូវបានរៀបចំឡើងជាមួយអ្នកពាក់ព័ន្ធរួមមាន តំណាងមកពីក្រសួងពាក់ព័ន្ធ មន្ទីរជុំវិញខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (គ.គ.ម.ខ) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (គ.គ.ម.ស) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (គ.គ.ម.ឃ) ភ្នាក់ងារសហប្រជាជាតិ និងអង្គការសង្គមស៊ីវិល បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ទាំងនោះ ។

គ.ជ.គ.ម សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅផងដែរដល់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានគាំទ្រជាថវិកានិងបច្ចេកទេស ក្នុងការរៀបចំសេចក្តីណែនាំប្រើប្រាស់ទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយបានដោយជោគជ័យ ។ យើងខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះ ក្រុមការងារ គ.ជ.គ.ម និង UNDP ដែលបានផ្តល់នូវការសម្របសម្រួល ជួបប្រឹក្សាយោបល់ការដាក់បញ្ចូលគ្នានូវគំនិតផ្សេងៗ រួមមាន បច្ចេកទេសនិងការគាំទ្រការរៀបចំសិក្ខាសាលា ។ សមាជិកក្រុមការងាររួមមាន ៖

- ឯកឧត្តម **ប៉ុន ណារិទ្ធិ** អគ្គលេខាធិការ គ.ជ.គ.ម
- ឯកឧត្តម **ជួប ស៊ីថន** ទីប្រឹក្សា គ.ជ.គ.ម
- ឯកឧត្តម **នាង ឆែន** ទីប្រឹក្សា គ.ជ.គ.ម និងជាប្រធាននាយកដ្ឋានឆ្លើយតបសង្គ្រោះបន្ទាន់និងស្តារឡើងវិញ
- លោក **ហ៊ុំ សុផុន** ប្រធានគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ UNDP
- លោក **សំ សុផល** មន្ត្រីគ្រប់គ្រងប្រព័ន្ធព័ត៌មានគ្រោះមហន្តរាយ UNDP

ជាចុងក្រោយ គ.ជ.គ.ម សូមថ្លែងអំណរគុណចំពោះតំណាងមកពីក្រសួងពាក់ព័ន្ធ អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិរួមមាន ខេត្ត ស្រុក និងឃុំដែលបានខិតខំប្រឹងប្រែងផ្តល់នូវគំនិតនិងយោបល់ដើម្បីធ្វើឱ្យទម្រង់របាយការណ៍ទិន្នន័យទាំងនេះសម្រេចបានជោគជ័យ ។ ទម្រង់របាយការណ៍ ទិន្នន័យគ្រោះមហន្តរាយនិងសេចក្តីណែនាំប្រើប្រាស់នេះ បង្កើតឡើងដោយមានប្រសិទ្ធភាពទៅបានដោយសារមានការចូលរួម ការផ្តល់យោបល់ ចំណេះដឹង និងបទពិសោធពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ។

# អក្សរកាត់

| | |
|---|---|
| គ.ជ.គ.ម | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| គ.គ.ម.ខ | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី/ខេត្ត |
| គ.គ.ម.ស | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក/ក្រុង/ខណ្ឌ/ |
| គ.គ.ម.ឃ | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ/សង្កាត់ |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CRC | កាកបាទក្រហមកម្ពុជា |
| CamDi | ប្រព័ន្ធគ្រប់គ្រងទិន្នន័យការបាត់បង់និងខូចខាតដោយសារគ្រោះមហន្តរាយនៅកម្ពុជា |
| MoAFF | ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| MoEYS | ក្រសួងអប់រំយុវជននិងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MoPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| CSO | អង្គការសង្គមស៊ីវិល |
| PDAFF | មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ |
| PDEYS | មន្ទីរអប់រំយុវជននិងកីឡា |
| PDH | មន្ទីរសុខាភិបាល |
| PDPWT | មន្ទីរសាធារណការ និងដឹកជញ្ជូន |
| PDRD | មន្ទីរអភិវឌ្ឍន៍ជនបទ |
| PDWRAM | មន្ទីរធនធានទឹក និងឧតុនិយម |
| RGC | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |

# I សារតារ

ប្រទេសកម្ពុជាគឺជាប្រទេសដែលងាយរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ និងគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស ដូចជា គ្រោះទឹកជំនន់ គ្រោះរាំង ស្ងួត ខ្យល់ព្យុះ រន្ទះបាញ់ បាក់ច្រាំងទន្លេ អគ្គីភ័យ និងជម្ងឺរាតត្បាត ។ ដោយសារតែការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយទាំងអស់នេះ បានកើតមានជាញឹកញាប់ ជាពិសេសក្នុងសវត្សទី២១នេះ ដូចជាទឹកជំនន់ឆ្នាំ២០១១ គ្រោះរាំងស្ងួតឆ្នាំ ២០១២ ទឹកជំនន់ឆ្នាំ២០១៣ ទឹកជំនន់ និងគ្រោះរាំងស្ងួតឆ្នាំ២០១៤ ខ្យល់កន្ត្រាក់អគ្គីភ័យរន្ទះបាញ់ និងជំងឺរាតត្បាតនានា ។ ឥទ្ធិពលនៃគ្រោះមហន្តរាយទាំងអស់នេះបានបង្កឱ្យមានគ្រោះថ្នាក់ ប៉ះពាល់ បាត់បង់ និងខូចខាត អាយុ ជីវិតមនុស្ស សត្វ ទ្រព្យសម្បត្តិ ជីវភាពរស់នៅ ដំណាំកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច បរិស្ថាន ។ល។

ឆ្លើយតបនឹងគ្រោះមហន្តរាយធំៗ ជាពិសសទឹកជំនន់ឆ្នាំ ២០១១ និង ២០១៣ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានខិតខំប្រឹងប្រែងដោយមិនបង្អង់ក្នុងការពង្រឹងនូវការត្រៀមរៀបចំនិងសម្របសម្រួល ដើម្បីការឆ្លើយតបគ្រោះមហន្តរាយឱ្យមានប្រសិទ្ធភាព និងល្អជាងមុន ដែលរួមមានការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យការបាត់បង់ ខូចខាត ដោយសារគ្រោះមហន្តរាយ ( CamDi ) ដែលមានគេហទំព័រ camdi.ncdm.gov.kh និងធ្វើឱ្យប្រសើរឡើងនូវទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ ។

កន្លងមកទិន្នន័យ/ព័ត៌មាននៃការប៉ះពាល់បាត់បង់ និងខូចខាត ដោយសារគ្រោះមហន្តរាយទាំងអស់នេះស្ថិតនៅដាច់ដោយឡែកៗពីគ្នា តាមក្រសួង មន្ទីរ រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌនិងមិនទាន់មានភាពស៊ីសង្វាក់គ្នានៅឡើយ ដោយទិន្នន័យដែលមាននៅថ្នាក់ជាតិមានភាពលំអៀងពីគ្នារវាងក្រសួងពាក់ព័ន្ធ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ បន្ទាប់ពីមានកិច្ចប្រជុំចង្អៀតរវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនៅវិមានសន្តិភាព ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ និងការដាក់ចេញសេចក្ដីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ២១១ ស.ជ.ណ.ស.រ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ត្រង់ចំណុចទី១០ បានតម្រូវឱ្យគ.ជ.គ.ម ពង្រឹងប្រព័ន្ធព័ត៌មាននិងរបៀបប៉ាន់ប្រមាណការខូចខាត និងសេចក្ដីត្រូវការដោយបង្កើតគំរូស្តង់ដាមួយស៊ីសង្វាក់គ្នា ក្នុងការប៉ាន់ប្រមាណការខូចខាត និងតម្រូវការសំរាប់ការគ្រប់គ្រងវិបត្តិ ដែលត្រូវលើកកំពស់នៅថ្នាក់មូលដ្ឋាន ។

តាមរយៈសេចក្ដីជូនដំណឹងលេខ២១១ស.ជ.ណ.ស.រ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ នេះ និងដោយមានការជួយឧបត្ថម្ភគាំទ្រជាថវិកា និងបច្ចេកទេសពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) នាយកដ្ឋានឆ្លើយតបសង្គ្រោះបន្ទាន់និងស្តារឡើងវិញនៃគ.ជ.គ.ម បានដឹកនាំ និងសម្របសម្រួលជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ មន្ត្រីជំនាញតាមក្រសួងមន្ទីរ ពាក់ព័ន្ធនានា ដើម្បីប្រមូលទិន្នន័យ គ្រោះមហន្តរាយដោយធម្មជាតិ និងដោយមនុស្សនៅកម្ពុជា ចាប់ពីឆ្នាំ ១៩៩៦ កន្លងមក សម្រាប់ចងក្រងស្តុកទុកក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រោះមហន្តរាយ(CamDi) តាមរយៈការឆ្លងកាត់កិច្ចប្រជុំនិងសិក្ខាសាលាពិគ្រោះយោបល់ជាច្រើនលើក ដែលមានអ្នកចូលរួមមកពីថ្នាក់រាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ ក្រសួង មន្ទីរ កាកបាទក្រហម និងសង្គមស៊ីវិលនានា សរុបប្រមាណជាង២០០០នាក់ ហើយបានធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងឈានដល់ការដាក់ឱ្យប្រើប្រព័ន្ធ CamDi នៅសណ្ឋាគារសាន់វ៉េ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៤ ក្រោមអធិបតីយភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **ញឹម វណ្ណដា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្ម

ពិសេស និងជាអនុប្រធានទី១នៃគ.ជ.គ.ម និង លោកស្រី **Claire Van der Vaeren** អ្នកសម្របសម្រួលសហប្រជាជាតិ និងប្រធានតំណាងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា ។ ជាមួយគ្នានេះដែរ ក្រុមការងារ ក៏បានរកឃើញថា របាយការណ៍ស្តីពីគ្រោះមហន្តរាយរបស់ថ្នាក់ខេត្ត-រាជធានី ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ ដែលកន្លងមកបានរៀបចំនិងណែនាំឱ្យប្រើប្រាស់ តាមលិខិតលេខ ២៨០ គ.ជ.គ.ម ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ (មើលឧបសម្ព័ន្ធ ៤) នៅមានភាពខ្វះចន្លោះ ដោយទិន្នន័យខ្លះពុំទាន់មានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ សម្រាប់ការដាក់បញ្ចូលទៅក្នុង ប្រព័ន្ធCamDi នៅឡើយ ដោយហេតុនេះ UNDP ក៏បានជួយបន្តពង្រឹងទម្រង់របាយការណ៍ទិន្នន័យនេះឡើងវិញ ។ ក្រោយពីបានចុះធ្វើការជួបប្រជុំពិភាក្សា និងណែនាំអនុវត្តប្រើប្រាស់ ទម្រង់របាយការណ៍ដល់ថ្នាក់ខេត្ត-រាជធានី ក្រុង-ស្រុក-ខណ្ឌ ឃុំ-សង្កាត់ មន្ត្រីជំនាញ និងមន្ទីរពាក់ព័ន្ធក្នុងខេត្តចំនួន៥ ៖ ព្រៃវែង ក្រចេះ កំពង់ធំ សៀមរាប កំពង់ឆ្នាំង និងការធ្វើសិក្ខាសាលាពិគ្រោះយោបល់ជាមួយថ្នាក់ក្រសួង ភ្នាក់ងារ សហប្រជាជាតិ អង្គការសង្គមស៊ីវិលមួយចំនួន យើងបានទទួលយកនូវសំណើរយោបល់ហើយបានធ្វើការកែលម្អជាបន្តបន្ទាប់ ជាពិសេស ការគាំទ្រ និងឯកភាពលើទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយទាំងប្រាំរបស់គ.ជ.គ.ម នៅក្នុងសិក្ខាសាលាចុងក្រោយ ដែលប្រារព្ធធ្វើនៅ សណ្ឋាគារ កាំបូឌីយ៉ាណា ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ ដែលមានអ្នកចូលរួមប្រមាណជាង ៦០នាក់ ក្រោមអធិបតីភាព ឯកឧត្តម **ប៉ុន ណ្ណារិទ្ធ** អគ្គលេខាធិការ គ.ជ.គ.ម ។

# II គោលបំណងនៃការដាក់ឱ្យប្រើប្រាស់ទម្រង់របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ

- ដើម្បីជួយសម្រួលដល់ថ្នាក់ក្រោមជាតិ ក្នុងការ កត់ត្រា/ដាក់បញ្ចូលនូវរាល់ទិន្នន័យ ឬតួលេខដែលបានធ្វើការប៉ាន់ប្រមាណនិងវាយតម្លៃ ដោយមានការឯកភាពគ្នារួចជាស្រេច ដើម្បីបញ្ជូនទៅថ្នាក់ជាតិទាន់ពេល និងច្បាស់លាស់ (ស៊ីគ្នាឬត្រូវគ្នា) ។
- ដើម្បីជួយដល់ថ្នាក់ដឹកនាំ រាជរដ្ឋាភិបាល/ក្រសួងស្ថាប័នធ្វើការសំរេចចិត្តបានឆាប់រហ័ស ត្រឹមត្រូវក្នុងការដាក់ចេញនូវវិធានការណ៍ អន្តរាគមន៍បន្ទាន់ទាន់ពេល និងមានប្រសិទ្ធភាព ។
- ដើម្បីផ្តល់ភាពងាយស្រួលដល់ដៃគូពាក់ព័ន្ធ/ម្ចាស់ជំនួយនានា ក្នុងការពិចារណា ផ្តល់នូវជំនួយមនុស្សធម៌បានសមស្របដល់ជនរងគ្រោះនិងការជួសជុលស្តារ និងការកសាងឡើងវិញ ។
- ដើម្បីកាត់បន្ថយការខ្ជះខ្ជាយពេលវេលា និងការប្រើប្រាស់ធនធានជាន់គ្នាហើយនិងការឈឺចាប់របស់ជនរងគ្រោះដើម្បីជួយអន្តរាគមន៍ទាន់ពេល មានប្រសិទ្ធភាព និងធ្វើឱ្យកិច្ចសហប្រតិបត្តិការរវាងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងជាតិ អន្តរជាតិ កាន់តែល្អប្រសើរ និងរឹងមាំជាងមុន ។

# III

# សេចក្តីណែនាំស្តីពីរបៀបធ្វើ
# របាយការណ៍ទិន្នន័យគ្រោះមហន្តរាយ




# ទម្រង់របាយការណ៍ទី១
# ការតាមដានត្រួតពិនិត្យព្រឹត្តិការណ៍មុនពេលគ្រោះមហន្តរាយ

## i). គោលបំណង

- ផ្តល់ព័ត៌មានបានច្បាស់លាស់និងទាន់ពេលពីស្ថានភាព គ្រោះអាសន្នមួយដែលអាចនឹងកើតមានឡើងនៅក្នុងមូលដ្ឋានសហគមន៍ដល់ គណៈកម្មាធិការគ្រប់គ្រង គ្រោះមហន្តរាយ ស្រុក/ខណ្ឌ/ក្រុង រាជធានី/ខេត្ត និងថ្នាក់ជាតិ ។
- កាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរដល់ មូលដ្ឋានសហគមន៍ ដោយសារឥទ្ធិពលគ្រោះអាសន្ន តាមរយៈការត្រៀមរៀបចំ វិធានការសង្គ្រោះនិងឆ្លើយតបបន្ទាន់ទាន់ពេល ។

## ii). ពេលវេលាកំណត់និងវិធីសាស្ត្រធ្វើរបាយការណ៍

- **ពេលវេលា**

របាយការណ៍នេះធ្វើដោយថ្នាក់ឃុំ/សង្កាត់ និងបញ្ជូនមកថ្នាក់ស្រុក/ក្រុង/ខណ្ឌ រាជធានី/ខេត្ត ក្នុងអម្លុងពេលពី ១ថ្ងៃ ទៅ៣ថ្ងៃ (ឬឆាប់ជាងនេះតាមការជាក់ស្តែង) ។

- **វិធីសាស្ត្រ**

នៅពេលពិនិត្យតាមដានស្ថានភាពគ្រោះអាសន្នមួយ ដែលអាចកើតមានឡើងក្នុងរយៈពេល ២ ឬ ៣ ថ្ងៃទៀតខាងមុខ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់

ឃុំ/សង្កាត់ត្រូវធ្វើការកោះប្រជុំ និងបែងចែកភារកិច្ចដល់ក្រុមប្រតិបត្តិការទាំងបីដើម្បីធ្វើសកម្មភាព និងប្រមូលព័ត៌មាន( *មើលឧបសម្ព័ន្ធ ៣*) ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ ។

### iii). របៀបសរសេររបាយការណ៍

***ក្បាលរបាយការណ៍*** ៖ សរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ ឈ្មោះខេត្ត/រាជធានី និងលេខកូដឃុំ/សង្កាត់ ។

#### ១. មុខសញ្ញាគ្រោះថ្នាក់

គូសសញ្ញា√ នៅក្នុងប្រអប់ □ ចំពោះមុខសញ្ញាគ្រោះថ្នាក់ណាមួយ ដែលបានកើតឡើង ដូចជាទឹកជំនន់ ឬ រាំងស្ងួតឬក៏សរសេរឈ្មោះមុខសញ្ញាគ្រោះថ្នាក់ណាមួយផ្សេងទៀត ត្រង់ចំណុចផ្សេងៗ (បើមិនមែនជាទឹកជំនន់ ឬរាំងស្ងួត)។

#### ២. កាលបរិច្ឆេទដែលនឹងមានគ្រោះមហន្តរាយ

សរសេរពីពេលវេលាដែលព្រឹត្តិការណ៍ មួយកើតមានឡើង តាមការពិនិត្យតាមដានជាក់ស្តែង និងសន្និដ្ឋាន។

#### ៣. ការតាមដានត្រួតពិនិត្យព្រឹត្តិការណ៍ និងព័ត៌មានគ្រោះអាសន្ន

➢ ចំពោះឃុំ/សង្កាត់នៅជាប់តាមដងទន្លេ ស្ទឹង ព្រែក បឹង ៖

នៅពេលរដូវទឹកឡើងជិតដល់មាត់ច្រាំង/ជិតដល់កំរិតប្រកាសអាសន្ន ចៅសង្កាត់/មេឃុំ ត្រូវចាត់ឱ្យមេភូមិ/សមាជិក តាមដានជាប្រចាំមើលបង្គោលកំរិតកម្ពស់ទឹក/បង្គោល ធ្លាប់ក្រិតចំណាំណាមួយ និងសរសេរកំរិតកម្ពស់ទឹកនៅលើក្តាខៀនផ្តល់ព័ត៌មាន (បើមាន) និងត្រូវផ្តល់ព័ត៌មានទៅចៅសង្កាត់/មេឃុំរៀងរាល់ថ្ងៃឬម៉ោង (បើកំរិតកម្ពស់ទឹក កើនឡើងខ្លាំង) ។

➢ ចំពោះឃុំ/សង្កាត់ នៅជាប់/ក្បែរជើងភ្នំ(ដូចជានៅខេត្តកំពង់ស្ពឺ,ពោធិ៍សាត់ ជាដើម) ៖

ក្នុងរដូវភ្លៀង/វស្សាឬពេលមានភ្លៀងធ្លាក់ជោគជាំជាប់ៗគ្នានៅតំបន់ភ្នំត្រូវតាមដានពី កំរិតទឹកភ្លៀងតាមព័ត៌មានព្យាករណ៍/អ្នកឡើងភ្នំ ពីបរិមាណទឹកដ៏សម្បើមដែលអាចនឹងហូរធ្លាក់ចាក់ចុះមកកាន់ភូមិ/ឃុំ នៅក្បែរ ។

➢ ចំពោះឃុំ/សង្កាត់ មានភូមិសាស្រ្តជាប់ក្បែរព្រំដែនប្រទេសជិតខាង ៖

ក្នុងរដូវភ្លៀង/វស្សា ត្រូវពិនិត្យតាមដានពីស្ថានភាពទឹកភ្លៀងនិងការបន្តធ្លាក់តាមការផ្សព្វផ្សាយព័ត៌មានព្យាករណ៍ ឬស្ថានភាពទឹកជំនន់នៅតាមស្រុក/ខេត្តជាប់ព្រំដែន តាមរយៈអ្នកចេញចូលធ្វើការ/រកស៊ី ឬក៏ការផ្តល់ដំណឹងពី គ.គ.ម.ខ/ខេត្ត ជាប់ព្រំដែន អំពីការអាចបាក់ធ្លាយទំនប់ឬការបង្ហូរទឹកចេញពីអាង ។

#### ៤. ការសន្និដ្ឋាននិងប៉ាន់ប្រមាណលើព្រឹត្តិការណ៍

តើអ្វីជាចរិតលក្ខណៈរបស់គ្រោះមហន្តរាយ ដូចរង្វាស់ទំហំ ល្បឿន និងវិសាលភាព របស់វាប្រៀបធៀបជាមួយព្រឹត្តិការណ៍មុនៗ ហើយអ្វីដែលបាត់បង់ខូចខាតធ្ងន់ធ្ងរ និងសូមបញ្ជាក់នូវអ្វីដែលអាចជាតម្រូវការចាំបាច់បន្ទាន់ត្រូវអន្តរាគមន៍ (សរសេរយ៉ាងច្រើន ៤ កថាខណ្ឌ) ។

#### ៥. ទំហំនៃឥទ្ធិពលការខូចខាតដែលនឹងកើតមានឡើង

*៥.១. ទីតាំងនិងចំនួនប្រជាជនដែលអាចនឹងទទួលរងឥទ្ធិពលដោយគ្រោះអាសន្ន ៖*

សរសេរឈ្មោះភូមិ ដែលអាចនឹងទទួលរងនូវឥទ្ធិពលនៃគ្រោះអាសន្ន និងបំពេញតួលេខ ប្រជាជនដែលអាចនឹងប៉ះពាល់/រងគ្រោះតាមការប៉ាន់ស្មាន ពិសេសចំនួនក្រុមងាយរងគ្រោះ ដែលមានស្រាប់នៅក្នុងតារាងស្ថិតិរបស់ភូមិ ។

*៥.២. ផ្ទះ ដំណាំកសិកម្ម និងសត្វពាហនៈដែលអាចនឹងទទួលរងឥទ្ធិពល ៖*

សរសេរឈ្មោះភូមិដាក់លាក់និងបំពេញតួលេខផ្ទៃដីដំណាំស្រូវ ដំណាំរួមផ្សំ ដំណាំ ឧស្សាហកម្ម និងសត្វពាហនៈដែលមានភូមិសាស្រ្តនៅតំបន់ទំនាប/ប្រឈមនឹងការប៉ះពាល់/ ជន់លិច តាមស្ថិតិមានស្រាប់របស់ភូមិ។

*៥.៣. អគារសាធារណៈផ្លូវគមនាគមន៍និងសេវាសំខាន់ៗដែលទំនងនឹងទទួលរងឥទ្ធិពល ៖*

សូមគូសសញ្ញា√ ក្នុងប្រអប់ □ បើសិនគិតថា សំណង់អគារផ្លូវនិងសេវាណា ដែលអាចនឹងទទួលរងឥទ្ធិពល /

ជន់លិច ។

## ៦. ការត្រៀមរៀបចំសង្គ្រោះបន្ទាន់

### ៦.១. ធនធាននិងសម្ភារៈបរិក្ខារដែលប្រើបាន / ការត្រៀមរៀបចំភស្តុភា / ទ្រព្យសម្បត្តិ / សមត្ថភាព៖

សរសេរឈ្មោះអង្គភាពដូចជា នគរបាលប៉ុស្តិ៍ សាលារៀន មណ្ឌលសុខភាព កាកបាទ ក្រហមឃុំ ឬអាជ្ញាធរឃុំ/សង្កាត់ ភូមិ ឬ ម្ចាស់(កម្មសិទ្ធិ) ដែលមានកម្លាំងអាចជួយសង្គ្រោះ ឬមានជាមធ្យោបាយ សម្ភារៈ បរិក្ខារនានា ដូចជាទូក កាណូត រថយន្ត ថ្នាំពេទ្យ ស្បៀង ប្រេង ថវិកា អាវពោង ខ្សែ សំបកកង់ឡាន ។ល។ សម្រាប់ឆ្លើយតប ពេលមានគ្រោះអាសន្ន និង បញ្ជាក់ឈ្មោះអ្នកទទួលខុសត្រូវ និង លេខទូរស័ព្ទទំនាក់ទំនងពេលមានព្រឹត្តិការណ៍កើតឡើង ។

### ៦.២. ទីសុវត្ថិភាព ៖

សរសេរឈ្មោះទីសុវត្ថិភាពដូចជា សាលារៀន មណ្ឌលសុខភាព វត្ត ទីទួល ផ្លូវ ដោយបញ្ជាក់អំពីទីតាំងស្ថិតនៅកន្លែងណា និងចម្ងាយផ្លូវពីភូមិ/ឃុំទៅកាន់ទីនោះ និង ចំនួន អគារ/បន្ទប់ដែលអាចស្នាក់នៅបានប៉ុន្មាននាក់ ហើយបញ្ជាក់ផងដែរពីអគ្គិសនី (ម៉ាស៊ីន ភ្លើង) ចំនួនបង្គន់អនាម័យ អណ្តូងទឹកស្អាត(ស្នប់/លូ) ប្រសិនបើមានក្នុងទីសុវត្ថិភាពនីមួយៗ ។

### ៦.៣. សកម្មភាពត្រៀមរៀបចំ/វិធានការដែលប្រកាន់យកដោយអាជ្ញាធរមូលដ្ឋាន ៖

សរសេររៀបរាប់ដោយសង្ខេបពីសកម្មភាពឬវិធានការដែលបានត្រៀមបម្រុង ដើម្បីសង្គ្រោះនិងឆ្លើយតបបន្ទាន់ពេលមានព្រឹត្តិការណ៍គ្រោះអាសន្នកើតមានឡើងដូចជា ៖

- ការប្រជុំក្រុមប្រឹក្សា និងក្រុមប្រតិបត្តិការទាំងបីរបស់ឃុំ/សង្កាត់ និងជាមួយអង្គការដៃគូឈរជើងក្នុងមូលដ្ឋាន (បើមាន) ។
- ការចាត់តាំងកម្លាំង(មេភូមិ)តាមដានស្ថានការណ៍ និងព័ត៌មាន និងរាយការណ៍ជាប្រចាំនិងសរសេរកំរិតកម្ពស់ទឹកនៅលើក្តារខៀនព័ត៌មាន(បើមាន) ឬក៏ផ្តល់សញ្ញាប្រកាសអាសន្ន(តាមការកំណត់ឯកភាពគ្នា)នៅពេលមានគ្រោះអាសន្នកើតមានឡើង ។
- បែងចែកកម្លាំងត្រៀមសង្គ្រោះ ឆ្លើយតបបន្ទាន់និងចុះណែនាំ ផ្សព្វផ្សាយ/បកស្រាយព័ត៌មានព្យាករណ៍ជូនដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់ងាយរងគ្រោះ ដើម្បីប្រុងប្រយ័ត្ន និងត្រៀមរៀបចំមធ្យោបាយ ឬទ្រព្យសម្បត្តិមានតម្លៃ ..ទុកជាមុន ។
- ការដាក់បង្ហាញផែនទី ទីសុវត្ថិភាពនៅតាមភូមិ/ឃុំ ដោយបញ្ជាក់ពីផ្លូវធ្វើដំណើរទៅកាន់ ទីសុវត្ថិភាពនីមួយៗ ឬ កន្លែងដែលត្រូវប្រមូលផ្តុំគ្នា ពេលទទួលបានសញ្ញាប្រកាសអាសន្ន ។

## ៧. ប្រភេទតម្រូវការដែលជាអាទិភាព

សរសេរអំពីតម្រូវការដែលចាំបាច់ ជាពិសេសការជួយអន្តរាគមន៍ សង្គ្រោះ ឆ្លើយតបបន្ទាន់ ដូចជាតម្រូវការកម្លាំងសង្គ្រោះ មធ្យោបាយសង្គ្រោះ ការព្យាបាលថែទាំសុខភាព ការការពារសុវត្ថិភាព/សន្តិសុខការសាងសង់ជម្រក ដែលសមស្របតាមស្ថានការណ៍ជាក់ស្តែង ដែលអាចនឹងកើតមាន ហើយដែលអាជ្ញាធរឃុំ/សង្កាត់ ពុំមានលទ្ធភាពអាចដោះស្រាយបានដោយខ្លួនឯង ។

## សមាសភាពធ្វើរបាយការណ៍

សរសេរឈ្មោះ និងមុខងារអ្នកធ្វើរបាយការណ៍ ចំនួនពីនាក់ដោយដាក់លេខទូរស័ព្ទ ដើម្បីងាយស្រួលទំនាក់ទំនង ពីភាគីពាក់ព័ន្ធនានា ពេលត្រូវការព័ត៌មានបន្ថែម ។

## ការចុះហត្ថលេខានិងប្រថាប់ត្រា

មេឃុំ/ចៅសង្កាត់ ត្រូវចុះថ្ងៃ ខែ ឆ្នាំ ឬលេខរបាយការណ៍ ឱ្យបានត្រឹមត្រូវនិងត្រូវចុះ ហត្ថលេខានិងប្រថាប់ត្រា មុននឹងបញ្ជូនទៅថ្នាក់ស្រុក/ក្រុង/ខណ្ឌ ខេត្ត/រាជធានី ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី/ខេត្ត......................................
សាលាស្រុក/ក្រុង/ខណ្ឌ.........................
ឃុំ/សង្កាត់..........................................
លេខកូដឃុំ.........................................
លេខ.................................................

## ទម្រង់របាយការណ៍ទី១ - ការតាមដានត្រួតពិនិត្យព្រឹត្តិការណ៍មុនពេលគ្រោះមហន្តរាយ

របាយការណ៍នេះត្រូវផ្ញើទៅ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក...........................

**១. មុខសញ្ញាគ្រោះថ្នាក់ ៖** ទឹកជំនន់ □ រាំងស្ងួត □ ផ្សេងៗ...................................

**២. កាលបរិច្ឆេទដែលនឹងមានគ្រោះមហន្តរាយ ៖** ថ្ងៃទី............. ខែ................. ឆ្នាំ................ នៅម៉ោង.................................

**៣. ការតាមដានត្រួតពិនិត្យព្រឹត្តិការណ៍ និងព័ត៌មានគ្រោះអាសន្ន** (សូមសរសេរខ្លឹមសារខ្លីៗតាមសេចក្តីណែនាំ)

| |
|---|
| |

**៤. ការសន្និដ្ឋាននិងប៉ាន់ប្រមាណលើព្រឹត្តិការណ៍ ៖** ..........................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

## ៥. ទំហំនៃឥទ្ធិពលការខូចខាតដែលនឹងកើតមានឡើង

### *៥.១. ទីតាំងនិងចំនួនប្រជាជនដែលអាចនឹងទទួលរងនូវឥទ្ធិពលដោយគ្រោះអាសន្ន*

| ឈ្មោះភូមិ | ចំនួនប្រជាជន | | | ក្រុមងាយរងគ្រោះ | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រួសារ | មនុស្ស (នាក់) | | ស្ត្រី (នាក់) | | កុមារ (នាក់) | | | | | | ជរា (នាក់) | | ជនពិការ (នាក់) | | កុមារពិការ (នាក់) | | មានជម្ងឺរ៉ាំរ៉ៃ HIV-ADS, របេង (នាក់) | | គ្រួសារក្រីក្រ | | | ស្ត្រីមេគ្រួសារ |
| | | | | មានគភ៌ | បំបៅកូន | 0-5 ឆ្នាំ | | 6-14 ឆ្នាំ | | 15-18 ឆ្នាំ | | 65ឆ្នាំឡើងទៅ | | | | | | | | គ្រួសារ | នាក់ | | |
| | | ស្រី | ប្រុស | | | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | | ស្រី | ប្រុស | |
| | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | |

ការបញ្ជាក់បន្ថែម (បើមាន) ៖ ..........................................................................................................................................................................................................................

..........................................................................................................................................................................................................................................................

### *៥.២. ផ្ទះ ដំណាំកសិកម្ម និងសត្វពាហនៈ ដែលអាចនឹងទទួលរងឥទ្ធិពល*

| ឈ្មោះភូមិ | ផ្ទះ (ខ្នង) | សំណាប (ហ.ត) | | សន្ទូង (ហ.ត) | | ស្រូវពងគ្រោះ(ហ.ត) | | ដំណាំរួមផ្សំ (ហ.ត) | | ប៉ះពាល់សត្វពាហនៈ (ក្បាល) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ប៉ះពាល់ | ប៉ះពាល់ | ខូចខាត | ប៉ះពាល់ | ខូចខាត | ប៉ះពាល់ | ខូចខាត | ប៉ះពាល់ | ខូចខាត | គោ/ក្របី | ជ្រូក |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ការបញ្ជាក់បន្ថែម (បើមាន) ៖ ..........................................................................................................................................................................................................................

..........................................................................................................................................................................................................................................................

..........................................................................................................................................................................................................................................................

### ៥.៣. អគារសាធារណៈ ផ្លូវគមនាគមន៍ និងសេវាសំខាន់ៗ ដែលទំនងនឹងទទួលរងឥទ្ធិពល

| ឈ្មោះភូមិ | សាលារៀន (កន្លែង) | មណ្ឌលសុខភាព (កន្លែង) | មន្ទីរពេទ្យបង្អែក (កន្លែង) | វត្ត (កន្លែង) | ផ្លូវ (កន្លែង) | ប្រភពទឹក (កន្លែង) | អគ្គិសនី (កន្លែង) | សេវាទំនាក់ទំនង (កន្លែង) | សេវាសំខាន់ៗផ្សេងទៀត | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

ការបញ្ជាក់បន្ថែម (បើមាន) ៖ ..........................................................................................

..........................................................................................

..........................................................................................

## ៦. ការត្រៀមរៀបចំសង្គ្រោះបន្ទាន់

### ៦.១. ធនធាននិងសម្ភារៈបរិក្ខារដែលប្រើបាន / ការត្រៀមរៀបចំកស្តុភា / ទ្រព្យសម្បត្តិ / សមត្ថភាព

| ឈ្មោះអង្គភាព/ អាជ្ញាធរមូលដ្ឋាន | កម្លាំងត្រៀម (នាក់) | ប្រភេទសម្ភារៈបរិក្ខារ/ភស្តុភារ | ចំនួន | ឯកតា | ចំណុះ/ទំហំ | ឈ្មោះ/លេខទូរស័ព្ទអ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ការបញ្ជាក់បន្ថែម (បើមាន) ៖ ..........................................................................................

..........................................................................................

..........................................................................................

### ៦.២. *ទីសុវត្ថិភាព (សាលារៀន,វត្ត,ទីទួល,ផ្លូវ.......)*

| ឈ្មោះទីសុវត្ថិភាព | អាសយដ្ឋានទីសុវត្ថិភាព | ចម្ងាយពីភូមិ/ឃុំ(គ.ម) ទៅកាន់ទីសុវត្ថិភាព | ចំនួនអគារ/បោះតង់ (ខ្នង/កន្លែង) | ម៉ាស៊ីនភ្លើង/បណ្តាញអគ្គិសនី (គ្រឿង) | ចំនួនបង្គន់អនាម័យ (បន្ទប់) | ចំនួនអណ្តូងទឹកស្អាត(កន្លែង) | ចំនួនមនុស្សអាចស្នាក់នៅបាន(នាក់) |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ការបញ្ជាក់បន្ថែម (បើជាទីសុវត្ថិភាពជាផ្លូវ ឬទីទួលទទេរគ្មានអ្វីទាំងអស់សូមបញ្ជាក់ជាទំហំ) ៖..........................................................................................

..........................................................................................

### ៦.៣. *សកម្មភាពត្រៀមរៀបចំ/វិធានការដែលប្រកាន់យកដោយអាជ្ញាធរមូលដ្ឋាន (សរសេរខ្លឹមសារខ្លីៗតាមសេចក្តីណែនាំ)*

### ៧. ប្រភេទតម្រូវការ ដែលជាអាទិភាព

| ប្រភេទតម្រូវការ | ឯកតា | ចំនួន | អធិប្បាយ |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |

ព័ត៌មានបន្ថែម (បើមាន) ៖ ..........................................................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

..........................................................................................................................................................................

**សមាសភាពធ្វើរបាយការណ៍**

ឈ្មោះ.......................................មុខងារ..................................................ទូរស័ព្ទ......................................អ៊ីម៉ែល............................................................

ឈ្មោះ.......................................មុខងារ..................................................ទូរស័ព្ទ......................................អ៊ីម៉ែល............................................................

ធ្វើនៅ...................,ថ្ងៃទី ................ខែ................ ឆ្នាំ.............

**មេឃុំ/ចៅសង្កាត់ និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ/សង្កាត់**



# ទម្រង់របាយការណ៍ទី២
# របាយការណ៍បន្ទាន់ ព្រឹត្តិការណ៍ក្នុងពេលគ្រោះមហន្តរាយ

## i). គោលបំណង

រាយការណ៍ជាបន្ទាន់ភ្លាមៗតាមអ្វីដែលអាចធ្វើទៅបាន (អាចទូរស័ព្ទមុន) នូវព្រឹត្តិការណ៍គ្រោះមហន្តរាយដែលកំពុងកើតមានហើយបានគំរាមកំហែងដល់អាយុជីវិតមនុស្ស សត្វ និង បង្កផលប៉ះពាល់ដល់ផ្ទះ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ... និង សកម្មភាពជួយ ទប់ទល់ អន្តរាគមន៍សង្គ្រោះ ឆ្លើយតបបន្ទាន់ ពីអាជ្ញាធរ/ផ្នែកពាក់ព័ន្ធ នៅក្នុងមូលដ្ឋានឃុំ/សង្កាត់ ឱ្យបានទាន់ពេលវេលា ។

## ii). ពេលវេលាកំណត់និងវិធីសាស្ត្រធ្វើរបាយការណ៍

➢ **ពេលវេលា**

ធ្វើដោយឃុំ/សង្កាត់ ផ្ញើជូនក្រុង/ស្រុក/ខណ្ឌ និងត្រូវបញ្ជូនមករាជធានី/ខេត្ត ហើយ និងមកគ.ជ.គ.ម ក្នុងអំឡុងពេលចាប់ពី៣ម៉ោង ទៅ ៦ម៉ោង (អាចទូរស័ព្ទបន្ទាន់ បើចាំបាច់) ។

➢ **វិធីសាស្ត្រ**

នៅពេលគ្រោះមហន្តរាយបានកើតឡើងភ្លាមៗ គណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយឃុំ ត្រូវចុះទៅដល់ទីកន្លែងដែលទទួលរងគ្រោះដើម្បីធ្វើសកម្មភាពជួយសង្គ្រោះបន្ទាន់ និងប្រមូលព័ត៌មានដើម្បីធ្វើរបាយការណ៍ពិនិត្យស្ថានភាព ។

## iii). របៀបសរសេររបាយការណ៍

***ក្បាលរបាយការណ៍*** ៖ សរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ ឈ្មោះខេត្ត/រាជធានី និងលេខកូដឃុំ/សង្កាត់ ។

### ១. មុខសញ្ញាគ្រោះថ្នាក់

គូសសញ្ញា√ នៅក្នុងប្រអប់ □ ព្រឹត្តិការណ៍ណាមួយដែលកំពុងកើតមានឡើង (ឧទាហរណ៍ដូចជាទឹកជំនន់)។

### ២. កាលបរិច្ឆេទនៃព្រឹត្តិការណ៍គ្រោះមហន្តរាយ

សរសេរថ្ងៃ ខែ ឆ្នាំ និងម៉ោង ព្រឹត្តិការណ៍កើតមានឡើង។

### ៣. ការពិពណ៌នាសង្ខេបនៃព្រឹត្តិការណ៍ដែលកំពុងកើតមាន

សរសេរអំពីស្ថានភាពគ្រោះអាសន្ន ដែលកំពុងតែគំរាមកំហែងដល់អាយុជីវិត និងប៉ះពាល់ ខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនានា តើវាមានសភាពធ្ងន់ធ្ងរដូចម្ដេចខ្លះ? ។

### ៤. ទីតាំងនិងប្រជាជនដែលទទួលរងឥទ្ធិពលនិងការជំលៀសចេញពីលំនៅដ្ឋាន

សរសេរឈ្មោះភូមិដែលរងគ្រោះ និងប៉ាន់ស្មានចំនួនប្រជាជនដែលទទួលរងផលប៉ះពាល់ និងចំនួនមនុស្ស/សត្វដែលបានជំលៀសចេញពីភូមិ។ចំពោះភូមិដែលទទួលរងគ្រោះធ្ងន់ធ្ងរ សូមគូសសញ្ញា √ នៅក្នុងប្រអប់ □ ។

### ៥. ប្រភេទជនរងគ្រោះ (ស្លាប់,របួស,បាត់ខ្លួន) និងទីកន្លែងឧបទ្ទវហេតុ

សរសេររាយតាមលំដាប់ពីប្រភេទរងគ្រោះ ដូចជា ស្លាប់, របួស,បាត់ខ្លួន ដោយបញ្ជាក់ ចំនួនអ្នករងគ្រោះ ជាមនុស្សពេញវ័យ/ចាស់/កុមារ ភេទប្រុស ឬស្រី មូលហេតុស្លាប់ដោយសារលង់ទឹក, ពស់ចឹក របួសដោយសារដើមឈើរលំលើ បាត់ខ្លួនដោយសារទឹកហូរបុកប៉ើង រកមិនទាន់ឃើញ និងបញ្ជាក់អំពីទីតាំងដែលកើតហេតុ នៅភូមិណា?

### ៦. ផលប៉ះពាល់ធ្ងន់ធ្ងរ ៖ ផ្ទះ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មធ្យោបាយ ឬ សេវាកម្មនានា

គូសសញ្ញា√នៅក្នុងទិន្នន័យប្រអប់□ណា ដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរឬខូចខាតទាំងស្រុង ។ ឧទាហរណ៍ បើមណ្ឌលសុខភាពខូចខាតធ្ងន់ធ្ងរ សូមគូសក្នុងប្រអប់ "មណ្ឌលសុខភាព □" ឬបើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតប៉ះពាល់ធ្ងន់ធ្ងរសូមគូសក្នុងប្រអប់"ទឹកស្អាត □" ។

### ៧. ការពិពណ៌នាសង្ខេបពីអ្វីដែលអាជ្ញាធរ/អ្នកពាក់ព័ន្ធកំពុងធ្វើ

សរសេររៀបរាប់ខ្លីៗ អំពីសកម្មភាពដែលអាជ្ញាធរឃុំ/សង្កាត់ ក្រុមប្រតិបត្តិការទាំងបី ផ្នែកពាក់ព័ន្ធនានា ឬអង្គការដៃគូដែលមានក្នុងមូលដ្ឋានកំពុងធ្វើដូចជា ៖

- ការជួយសង្គ្រោះ ការសង់ជម្រក
- ការជួយដឹកជញ្ជូនជំលៀសប្រជាជន
- ការការពារសន្តិសុខ សណ្ដាប់ធ្នាប់
- ការរុករកសាកសព ការជួយព្យាបាលរបួស ។ល។

### ៨. សេចក្ដីត្រូវការបន្ទាន់

គូសសញ្ញា√ នៅក្នុង □ បាទ(បើត្រូវការ) និង គូសសញ្ញា√ នៅក្នុង □ ទេ(បើមិនត្រូវការ) និងសូមបញ្ជាក់អំពីមូលហេតុច្បាស់លាស់នៃតម្រូវការ តើសម្រាប់ប្រើប្រាស់ធ្វើអ្វី? សម្រាប់មនុស្សប៉ុន្មាននាក់? ហើយសូមគូសសញ្ញា√ នៅក្នុងប្រអប់□បើសិនគិតថា វាជាប្រភេទ តម្រូវការដែលមានអាទិភាពខ្ពស់ ។

### សមាសភាពធ្វើរបាយការណ៍

សរសេរឈ្មោះនិងមុខងារអ្នកធ្វើរបាយការណ៍ចំនួនពីរនាក់ដោយដាក់លេខទូរស័ព្ទ ដើម្បីងាយស្រួលទំនាក់ទំនងពីភាគីពាក់ព័ន្ធនានា ពេលត្រូវការព័ត៌មានបន្ថែម ។

### ការចុះហត្ថលេខានិងប្រថាប់ត្រា

មេឃុំ/ចៅសង្កាត់ត្រូវចុះថ្ងៃ ខែ ឆ្នាំ ឬលេខរបាយការណ៍ឱ្យបានត្រឹមត្រូវនិងត្រូវចុះហត្ថលេខា ហើយប្រថាប់ត្រាមុននឹងបញ្ជូនទៅថ្នាក់ស្រុក/ក្រុង/ខណ្ឌ ខេត្ត/រាជធានី ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី/ខេត្ត..........................................
សាលាស្រុក/ក្រុង/ខណ្ឌ............................
ឃុំ/សង្កាត់.............................................
លេខកូដឃុំ...........................................
លេខ...................................................

## ទម្រង់របាយការណ៍ទី២ - របាយការណ៍បន្ទាន់ ព្រឹត្តិការណ៍ក្នុងពេលគ្រោះមហន្តរាយ ( ១ម៉ោង - ៦ម៉ោង )

របាយការណ៍នេះត្រូវផ្ញើទៅ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក..........................

**១. មុខសញ្ញាគ្រោះថ្នាក់ ៖** ទឹកជំនន់ ☐ ខ្យល់ព្យុះ ☐ អគ្គីភ័យ ☐ ផ្សេងៗ....................

**២. កាលបរិច្ឆេទនៃព្រឹត្តិការណ៍គ្រោះមហន្តរាយ ៖** ថ្ងៃទី............ ខែ............ ឆ្នាំ.................. នៅម៉ោង..........................................

**៣. ការពិពណ៌នាសង្ខេបនៃព្រឹត្តិការណ៍ដែលកំពុងកើតមាន ៖**..............................................................................................................

..............................................................................................................................................................

**៤. ទីតាំង និងប្រជាជនដែលទទួលរងឥទ្ធិពលនិងការជំលៀសចេញពីលំនៅដ្ឋាន**

| ឈ្មោះភូមិ | ប្រជាជនដែលប៉ះពាល់ | | ប្រជាជនជំលៀសចេញ | | ជំលៀសសត្វពាហនៈ ( ក្បាល ) | |
|---|---|---|---|---|---|---|
| | គ្រួសារ | នាក់ | គ្រួសារ | នាក់ | គោ/ក្របី | ជ្រូក |
| ☐ | | | | | | |
| ☐ | | | | | | |
| ☐ | | | | | | |
| ☐ | | | | | | |
| ☐ | | | | | | |
| ☐ | | | | | | |

សូមគូសសញ្ញាខ្វែង **x** នៅក្នុងប្រអប់ □ ចំពោះភូមិដែលទទួលរងគ្រោះធ្ងន់ធ្ងរ ការបញ្ជាក់បន្ថែម(បើមាន) ៖.................................................................................................

.................................................................................................................................................................................................

.................................................................................................................................................................................................

.................................................................................................................................................................................................

## ៥. ប្រភេទជនរងគ្រោះ (ស្លាប់,របួស,បាត់ខ្លួន) និងទីកន្លែងឧបទ្ទវហេតុ

| ប្រភេទរងគ្រោះ | ចំនួនអ្នករងគ្រោះ (នាក់) | | | | | មូលហេតុ | ទីតាំងកើតហេតុ |
|---|---|---|---|---|---|---|---|
| | សរុប | មនុស្សពេញវ័យ(១៨ឆ្នាំឡើង) | | កុមារ (ក្រោម១៨ឆ្នាំ) | | | |
| | | ស្រី | ប្រុស | ស្រី | ប្រុស | | |
| ស្លាប់ | | | | | | | |
| របួស | | | | | | | |
| បាត់ខ្លួន | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ការបញ្ជាក់បន្ថែម(បើមាន) ៖.................................................................................................................................................

.................................................................................................................................................................................................

.................................................................................................................................................................................................

**៦. ផលប៉ះពាល់ធ្ងន់ធ្ងរ ៖** ផ្ទះ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មធ្យោបាយ ឬសេវាកម្មនានា សូមគូសសញ្ញាខ្វែង **x** នៅក្នុងប្រអប់ □ ចំពោះផលប៉ះពាល់លើអ្វីដែលបានទទួលរងគ្រោះធ្ងន់ធ្ងរ ៖

| | | | | | |
|---|---|---|---|---|---|
| ផ្ទះ □ | ទ្រព្យសម្បត្តិ □ | សាលារៀន □ | មណ្ឌលសុខភាព □ | វត្ត □ | អគ្គិសនី □ |
| ផ្លូវជាតិ □ | ផ្លូវខេត្ត □ | ផ្លូវក្រុង □ | ផ្លូវជនបទ □ | ផ្លូវលំ □ | ទឹកស្អាត □ |
| ស្ពាន □ | លូ □ | ប្រព័ន្ធស្រោចស្រព □ | បរិស្ថាន □ | អាជីវកម្ម □ | ................. □ |
| .......... □ | ................. □ | ................. □ | ................. □ | ................. □ | ................. □ |

**៧. ការពិពណ៌នាសង្ខេបពីអ្វីដែលអាជ្ញាធរ/អ្នកពាក់ព័ន្ធកំពុងធ្វើ** ( សរសេរតាមសេចក្តីណែនាំ )

**៨. សេចក្តីត្រូវការបន្ទាន់**

- សូមគូសសញ្ញា √ នៅក្នុង { } បាទ/ចាស ( បើត្រូវការ ) និង គូសសញ្ញា √ នៅក្នុង { }ទេ ( បើមិនត្រូវការ ) និង
- សូមបញ្ជាក់អំពីមូលហេតុច្បាស់លាស់នៃតម្រូវការ តើសម្រាប់ប្រើប្រាស់ធ្វើអ្វី? សម្រាប់មនុស្ស ប៉ុន្មាននាក់?....
- សូមគូសសញ្ញា √ នៅក្នុងប្រអប់ □ ខាងមុខប្រភេទតម្រូវការ បើសិនគិតថាវាជាប្រភេទមានអាទិភាពខ្ពស់

| ប្រភេទតម្រូវការ | បាទ/ចាស | ទេ | អធិប្បាយអំពីមូលហេតុនៃតម្រូវការ |
|---|---|---|---|
| ☐ មធ្យោបាយសង្គ្រោះ | { } | { } | |
| ☐ កម្លាំងរុករកនិងសង្គ្រោះ | { } | { } | |
| ☐ ការព្យាបាលនិងថែទាំសុខភាព | { } | { } | |
| ☐ ជម្រកបណ្ដោះអាសន្ន | { } | { } | |
| ☐ សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ | { } | { } | |
| ☐ ទឹកស្អាត | { } | { } | |
| ☐ ស្បៀងអាហារ | { } | { } | |
| ☐ ការពារសុវត្ថិភាព សណ្ដាប់ធ្នាប់ | { } | { } | |
| ☐ អនាម័យ | { } | { } | |
| ☐ ......................... | { } | { } | |
| ☐ .......................... | { } | { } | |
| ☐ ........................ | { } | { } | |
| ☐ ........................ | { } | { } | |

**សមាសភាពធ្វើរបាយការណ៍**

ឈ្មោះ.......................................មុខងារ...........................ទូរស័ព្ទ..........................អ៊ីម៉ែល.....................................

ឈ្មោះ.......................................មុខងារ.......................... ទូរស័ព្ទ......................... អ៊ីម៉ែល.....................................

ធ្វើនៅ..................,ថ្ងៃទី.............ខែ..............ឆ្នាំ.........

**មេឃុំ/ចៅសង្កាត់ និងជាប្រធាន**

**គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ/សង្កាត់**



# ទម្រង់របាយការណ៍ទី៣
# របាយការណ៍បឋម ព្រឹត្តិការណ៍ក្នុងពេលគ្រោះមហន្តរាយ

## i). គោលបំណង

រាយការណ៍ជាបន្ទាន់ នូវព្រឹត្តិការណ៍គ្រោះមហន្តរាយ ដែលកំពុងកើតមាន ហើយបង្កផលប៉ះពាល់លើអាយុជីវិត មនុស្ស សត្វ លំនៅដ្ឋាន ទ្រព្យសម្បត្តិ ជីវភាពរស់នៅ ការពឹងអាស្រ័យ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ បរិស្ថាន... និងសកម្មភាព/វិធានការជួយ អន្តរាគមន៍បន្ទាន់របស់ អាជ្ញាធរ/ផ្នែកពាក់ព័ន្ធក្នុងមូលដ្ឋានដល់ជនរងគ្រោះ ។

## ii). ពេលវេលាកំណត់និងវិធីសាស្ត្រធ្វើរបាយការណ៍

➢ **ពេលវេលា**

ធ្វើដោយឃុំ/សង្កាត់ ផ្ញើជូនមកក្រុង/ស្រុក/ខណ្ឌនិងត្រូវ បញ្ជូនមករាជធានី/ខេត្ត ហើយ និងមកគ.ជ.គ.ម ក្នុង អំលុងពេលចាប់ ពី១ថ្ងៃ ទៅ ៣ថ្ងៃ ។

➢ **វិធីសាស្ត្រ**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ត្រូវបើក កិច្ចប្រជុំជាមួយក្រុមប្រតិបត្តិការទាំងបី និងអង្គការដៃគូ ដែលមាននៅមូលដ្ឋានរបស់ខ្លួន ដើម្បីធ្វើសកម្មភាពជួយ សង្គ្រោះនិងឆ្លើយតប និងប្រមូលព័ត៌មានដើម្បីដាក់បញ្ចូល ក្នុងរបាយកាណ៍ ។

## iii). របៀបសរសេររបាយការណ៍

***ក្បាលរបាយការណ៍*** ៖ សរសេរឈ្មោះ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ ឈ្មោះខេត្ត/រាជធានី និងលេខកូដឃុំ/ សង្កាត់ ។

***១. មុខសញ្ញាគ្រោះថ្នាក់***

គូសសញ្ញា√ នៅក្នុងប្រអប់ □ ព្រឹត្តិការណ៍ណាមួយ

ដែលកំពុងកើតមានឡើង (ឧទាហរណ៍ដូចជាទឹកជំនន់)។

### ២. កាលបរិច្ឆេទនៃព្រឹត្តិការណ៍គ្រោះមហន្តរាយ

សរសេរថ្ងៃ ខែ ឆ្នាំ និងម៉ោងព្រឹត្តិការណ៍កើតមានឡើង។

### ៣. ស្ថានភាពនិងការតំរាមកំហែងបច្ចុប្បន្ន

គូសសញ្ញា√ ក្នុងប្រអប់ □ តាមស្ថានភាព ជាក់ស្តែង ដែលកំពុងកើតមានបច្ចុប្បន្ន ខ្លាំងជាមុន ខ្សោយជាងមុន ឬ នៅទ្រឹង ។

### ៤. ការពិពណ៌នាសង្ខេបនៃព្រឹត្តិការណ៍ដែលកំពុងកើតមាន

តើអ្វីជាចរិតលក្ខណៈរបស់គ្រោះមហន្តរាយ ដូចរង្វាស់ ទំហំ ល្បឿន និងវិសាលភាព របស់វាប្រៀបធៀបជាមួយព្រឹត្តិការណ៍មុនៗ ហើយអ្វីដែលបាត់បង់ខូចខាតធ្ងន់ធ្ងរ និងសូមបញ្ជាក់នូវអ្វីដែលអាចជាតម្រូវការចាំបាច់បន្ទាន់ត្រូវអន្តរាគមន៍ (សរសេរយ៉ាងច្រើន ៤ កឋខណ្ឌ) ។

### ៥. ទីតាំងដែលកំពុងទទួលរងឥទ្ធិពល និងទីតាំងដែលទំនងនឹងរងឥទ្ធិពលបន្ថែម

សរសេរឈ្មោះភូមិដែលកំពុងទទួលរងគ្រោះ និងបញ្ជាក់ពីចំនួនប្រជាជនប៉ះពាល់ និងប្រជាជនរងគ្រោះ ដោយលំអិតតួលេខជនងាយរងគ្រោះដូចជា ស្ត្រីមានគភ៌ ស្ត្រីមានកូនខ្ចី កុមារអាយុក្រោម 5 ឆ្នាំ ពី 6-14ឆ្នាំ ពី15-18 ឆ្នាំ ចាស់ជរាចាប់ពីអាយុ65ឆ្នាំឡើង ជនពិការ និងចំនួនគ្រួសារក្រីក្រ ទាំងកំរិត១ និងកំរិត ២ ។

ក្នុងករណីគ្រោះមហន្តរាយមានឥទ្ធិពលខ្លាំង ហើយតាមការប៉ាន់ស្មានជាក់ស្តែង និងផ្អែកតាមព័ត៌មានព្យាករណ៍ និងបទពិសោធន៍កន្លងមកនោះអាចសន្និដ្ឋានថា ទឹកជំនន់នឹងបន្តលិចដល់ភូមិផ្សេងទៀត សូមសរសេរឈ្មោះភូមិ និងតួលេខក្នុងតារាង "តាមស្ថិតិដែលមានស្រាប់ក្នុងតារាងខាងក្រោម" ។

### ៦. មនុស្សរងគ្រោះថ្នាក់ (ស្លាប់,របួស,បាត់ខ្លួន)

សរសេរឈ្មោះភូមិ ប្រភេទរងគ្រោះថ្នាក់(ស្លាប់, របួស, បាត់ខ្លួន) ឈ្មោះជនរងគ្រោះ ភេទ អាយុ ពេលវេលាដែលបានទទួលរងគ្រោះ និងបញ្ជាក់អំពីមូលហេតុ អំពីការស្លាប់ បាត់ខ្លួន ឬការរងរបួស ។

### ៧. ជំលៀស

សរសេរ អំពីឈ្មោះភូមិដែលមានប្រជាជនជំលៀសចេញសរុប ប៉ុន្មានគ្រួសារ ស្មើនឹងមនុស្សប៉ុន្មាននាក់? ទៅកាន់ទីសុវត្ថិភាពឈ្មោះអ្វី មានប៉ុន្មានគ្រួសារ ស្មើនឹងមនុស្សប្រុស ប៉ុន្មាននាក់? ស្រីប៉ុន្មាននាក់? និងមានគ្រួសារ ស្មើនឹងមនុស្សប៉ុន្មាននាក់? បានទៅរស់នៅតាមផ្ទះសាច់ញាតិ ។

#### ៧.១. ស្ថានភាព/សេចក្តីត្រូវការនៃប្រជាជនក្នុងទីសុវត្ថិភាព

សរសេរឈ្មោះទីទីសុវត្ថិភាព និងឈ្មោះទីតាំងនៅក្រៅទីសុវត្ថិភាពនីមួយៗ ដែលប្រជាជនកំពុងស្នាក់នៅមានចំនួនប៉ុន្មានគ្រួសារ ស្មើនឹងមនុស្សប្រុសប៉ុន្មាននាក់? ប៉ុន្មាន នាក់ស្រី? ហើយក្នុងនោះបញ្ជាក់ពីចំនួនគ្រួសារតាមប្រភេទប្រជាជនដែលកំពុងប្រឈមឬខ្វះខាត ដូចជាជម្រកស្នាក់នៅ ? ទឹកស្អាតប្រើប្រាស់? ស្បៀងអាហារ? សម្លៀកបំពាក់? សម្ភារៈសំរាប់ដាំស្ល? ធុងសំរាប់ដាក់ទឹកប្រើ? បង្គន់? អនាម័យ?

### ៨. ឥទ្ធិពលនិងការខូចខាត

#### ៨.១. ផ្ទះ, និងសំណង់សាធារណៈ

សរសេរតួលេខប្រភេទសំណង់ ដូចជាផ្ទះប៉ុន្មានខ្នង មណ្ឌលសុខភាព, សាលារៀន, វត្ត ប៉ុន្មានកន្លែង ដែលទទួលរងផលប៉ះពាល់តិចតួច? ប៉ះពាល់មធ្យម? ប៉ះពាល់ធ្ងន់ធ្ងរ ?

#### ៨.២. ទ្រព្យសម្បត្តិពិសេស និងមានតម្លៃ

សរសេររាយឈ្មោះទ្រព្យសម្បត្តិ/វត្ថុ មានតម្លៃ ដែលបានបាត់បង់ឬខូចខាតដោយ បញ្ជាក់ពីចំនួន /បរិមាណ និងមូលហេតុនៃការបាត់បង់ឱ្យបានច្បាស់លាស់ (ឧ. ដោយសារទឹកលិច, ធ្លាក់ចូលក្នុងទឹក, ចោរលួច) ។

#### ៨.៣. ទីតាំងសេវាសំខាន់ៗដែលពាក់ព័ន្ធជីវភាពរស់នៅប្រចាំថ្ងៃ

សរសេរតួលេខសេវាសាធារណៈឬការពឹងអាស្រ័យនានា ដូចជា ទីតាំងផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ទីផ្សារ និង ទីតាំងម៉ាស៊ីនកិនស្រូវ សេវាទំនាក់ទំនងដែលបានប៉ះពាល់ ប៉ុន្មានកន្លែង? និងផ្អាកសកម្មភាព/ដំណើរការ ប៉ុន្មានកន្លែង?

*៨.៤. វិស័យអប់រំ*

សរសេរឈ្មោះភូមិ និងចំនួនសាលារៀនដែលទទួលរងប៉ះពាល់និងខូចខាតមធ្យម និងធ្ងន់ធ្ងរ ប៉ុន្មាន កន្លែងនិងបញ្ជាក់ឈ្មោះសម្ភារៈបរិក្ខា ដែលមានលក្ខណៈពិសេសមានអ្វីខ្លះ ចំនួនប៉ុន្មាន ដែលបានប៉ះពាល់បាត់បង់និងខូច? ហើយសូមបញ្ជាក់ឈ្មោះសាលារៀនដែលមិនអាចដំណើរការសិក្សាបានឬបិទទ្វារបណ្តោះអាសន្ន និងចំនួនសិស្សដែលមិនអាចចូលរៀន។

*៨.៥. វិស័យកសិកម្ម*

សរសេរតួលេខ ដំណាំស្រូវ ដំណាំឧស្សាហកម្ម ដំណាំរួមផ្សំដែលទទួលរងផលប៉ះពាល់ ប៉ុន្មានហិកតា? សត្វគោ ក្របី ជ្រូក ដំលៀសចេញប៉ុន្មានក្បាល? និង ងាប់, បាត់ ប៉ុន្មាន ក្បាល ?

*៨.៦. វិស័យសាធារណៈការនិងដឹកជញ្ជូន*

៨.៦.១. ផ្លូវជាតិ, ផ្លូវខេត្ត, ផ្លូវក្រុង និងសំណង់សិល្បការ្យ

សរសេរឈ្មោះទីតាំង និងតួលេខផ្លូវជាតិ ផ្លូវជាតិ, ផ្លូវខេត្ត, ផ្លូវក្រុង និងសំណង់សិល្បការ្យដែលមានលូប្រអប់ លូមូល ឬ ភ្លឺប្រឡាយប៉ុន្មានកន្លែងដែលបានប៉ះពាល់ដាច់?

៨.៦.២. ស្ពានបេតុង, ស្ពានបេឡេគ៏ និងស្ពានឈើ

សរសេរឈ្មោះទីតាំងនិងតួលេខស្ពានបេតុង ស្ពានបេឡេគ៏ និងស្ពានឈើដែលបានលិច ហូរច្រោះ និងបាក់ឬស្រុត ប៉ុន្មានកន្លែង?

*៨.៧. វិស័យអភិវឌ្ឍន៍ជនបទ*

៨.៧.១. ផ្លូវ និង ស្ពាន

សរសេរឈ្មោះទីតាំង និងតួលេខ ផ្លូវកៅស៊ូ/ផ្លូវបេតុង, ផ្លូវដី/ផ្លូវដីក្រហម, ស្ពានបេតុង, ស្ពានបេឡេគ៏/ស្ពានឈើ ប៉ុន្មាន កន្លែងដែលបានលិច? ហូរច្រោះ? បាក់ឬស្រុត?

៨.៧.២. លូ, អណ្តូងទឹក, បង្គន់

សរសេរឈ្មោះទីតាំង និងតួលេខ អំពីលូប្រអប់, លូមូល អណ្តូងស្នប់, អណ្តូងលូ, ស្រះ ទឹក, បង្គន់ចាក់ទឹកនិងបង្គន់ស្ងួតប៉ុន្មានកន្លែងដែលបានលិច? ហូរច្រោះ? បាក់ឬស្រុត?

*៨.៨. វិស័យធនធានទឹកនិងឧតុនិយម*

សរសេរឈ្មោះទីតាំង និងតួលេខទំនប់, អាងស្តុកទឹក, ប្រឡាយមេ, ប្រឡាយរង, និង សំណង់សិល្បៈការ្យ ដូចជា៖ សំណង់ដោះទឹក, ចែកចាយទឹក, ស្ទាក់ទឹក, ទំនប់បង្ហៀរ និងក្បាលហុង មានប៉ុន្មានម៉ែត្រ? ប៉ុន្មានកន្លែង? ដែលបានលិចនិងដាច់ ។

*៨.៩. វិស័យឧស្សាហកម្ម*

សរសេរឈ្មោះនិងតួលេខ រោងចក្រ, ម៉ាស៊ីនកិនស្រូវ, ឃ្លាំងស្តុក, សិប្បកម្ម, កសិដ្ឋាន, សហគ្រាស មានចំនួនប៉ុន្មានកន្លែងដែលបានលិច? និងប៉ុន្មានកន្លែងដែលដំណើរការមិនបានឬផ្អាកជាបណ្តោះអាសន្ន ?

## *៩. ជំនួយសង្គ្រោះបន្ទាន់ដែលបានទទួល*

សរសេរឈ្មោះក្រសួង/ស្ថាប័ន អង្គភាព អង្គការ, សមាគម ក្រុមហ៊ុន ថ្នាក់ដឹកនាំជាន់ខ្ពស់ សប្បុរសជន ។ល។ ដែលបានផ្តល់ជំនួយចែកជូនដល់ជនរងគ្រោះ មានដូចជា អង្ករ មី ត្រីខកំប៉ុង ទឹកសុទ្ធ បានប៉ុន្មានគ្រួសារ? ស្មើនឹងមនុស្សប៉ុន្មាននាក់ ? នៅទីតាំងប្រមូលផ្តុំ/ ទីសុវត្ថិភាពឈ្មោះអ្វី? និងបញ្ជាក់ពីពេលវេលាដែលបានចែកចាយឱ្យបានច្បាស់លាស់នៅពេលណា?

## *១០. សង្ខេបសកម្មភាពសំខាន់ៗដែលបានធ្វើ ចាប់តាំងពីពេលកើតហេតុមកដល់បច្ចុប្បន្ន*

សរសេរសង្ខេបខ្លីៗ ពីសកម្មភាពនានា ដែលអាជ្ញាធរ ឃុំ/សង្កាត់ក្រុង/ស្រុក,ខណ្ឌ រាជ-ធានី/ខេត្ត ក្រសួងស្ថាប័ន អង្គភាព ដៃគូពាក់ព័ន្ធ សប្បុរសជន សមាគម, ក្រុមហ៊ុន

នានា ។ល។ ដែលកំពុងបានធ្វើកន្លងមក មកដល់ពេលនេះ (ឧ.ដូចជាការរក្សាសណ្តាប់ធ្នាប់, ការថែទាំសុខភាព, ការអប់រំផ្សព្វផ្សាយ, ការផ្តល់ជំនួយសង្គ្រោះ ។ល។)

### *១១. ការឱ្យយោបល់/តម្រូវការជំនួយសង្គ្រោះបន្ទាន់*

សរសេរអំពីប្រភេទតម្រូវការដែលចាំបាច់បន្ទាន់ សំរាប់ជួយដោះស្រាយបញ្ហាប្រឈមនានា ដូចជា ការកើតមានជម្ងឺគ្រុនក្តៅ, ជម្ងឺរាគ, កង្វះទឹកស្អាតប្រើប្រាស់, កង្វះស្បៀង អាហារ និងអធិប្បាយអំពីការប្រើប្រាស់សំរាប់ផ្តល់ជូនដល់ជនរងគ្រោះចំនួនប៉ុន្មានគ្រួសារ ស្មើនឹងមនុស្សប៉ុន្មាននាក់ នៅទីសុវត្ថិភាពឈ្មោះអ្វី ។

### *១២. ការពិពណ៌នាសង្ខេបពីស្ថានការណ៍បច្ចុប្បន្ន និងការព្យាករណ៍ពេលខាងមុខ*

សរសេរសង្ខេបខ្លីៗ អំពីស្ថានការណ៍ដែលកំពុងកើតមាននាពេលបច្ចុប្បន្ន តើវាមានលក្ខណៈដូចម្តេច ដូចជាព្រឹត្តិការណ៍ នោះនៅតែមានសភាពខ្លាំងជាងមុនខ្សោយជាងមុន ឬ នៅទ្រឹង? ជាមួយគ្នានេះ បើតាមការពិនិត្យតាមដានជាក់ស្តែង និងតាមប្រភពព័ត៌មានព្យាករណ៍ផ្សេងៗ អាចវាយតម្លៃ/ប៉ាន់ស្មានថា ព្រឹត្តិការណ៍នេះអាចបន្តគំរាមកំហែងកាន់តែខ្លាំង ក្នុងរយៈពេលប៉ុន្មានថ្ងៃទៀតខាងមុខ ឬក៏អាចថយចុះវិញ ។

### *សមាសភាពធ្វើរបាយការណ៍*

សរសេរឈ្មោះនិងមុខងារអ្នកធ្វើរបាយការណ៍ ចំនួនពីរនាក់ដោយដាក់លេខទូរស័ព្ទ ដើម្បីងាយស្រួលទំនាក់ទំនងពីភាគីពាក់ព័ន្ធនានា ពេលត្រូវការព័ត៌មានបន្ថែម ។

### *ការចុះហត្ថលេខានិងប្រថាប់ត្រា*

មេឃុំ/ចៅសង្កាត់ ត្រូវចុះថ្ងៃ ខែ ឆ្នាំ ឬលេខរបាយការណ៍ឱ្យបានត្រឹមត្រូវ និងត្រូវចុះហត្ថលេខាហើយប្រថាប់ត្រាមុននឹងបញ្ជូនទៅថ្នាក់ស្រុក/ក្រុង/ខណ្ឌ ខេត្ត/រាជធានី ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី/ខេត្ត.............................................
សាលាស្រុក/ក្រុង/ខណ្ឌ................................
ឃុំ/សង្កាត់.................................................
លេខកូដឃុំ...............................................
លេខ.....................................................

## ទម្រង់របាយការណ៍ទី៣ - របាយការណ៍បឋម ព្រឹត្តិការណ៍ក្នុងពេលគ្រោះមហន្តរាយ ( ១ថ្ងៃ – ៣ថ្ងៃ )

របាយការណ៍នេះត្រូវផ្ញើទៅ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក..........................

**១. មុខសញ្ញាគ្រោះថ្នាក់ ៖** ទឹកជំនន់ □ រាំងស្ងួត □ ផ្សេងៗ................................
**២. កាលបរិច្ឆេទនៃព្រឹត្តិការណ៍គ្រោះមហន្តរាយ ៖** ពីថ្ងៃទី ...........ខែ...............ឆ្នាំ................. ម៉ោង..................................
**៣. ស្ថានភាពនិងការគំរាមកំហែងបច្ចុប្បន្ន ៖** ខ្លាំងជាងមុន □ ខ្សោយជាងមុន □ នៅទ្រឹង □ ផ្សេងៗ ...............................
**៤. ការពិពណ៌នាសង្ខេបនៃព្រឹត្តិការណ៍ដែលកំពុងកើតមាន ៖**.....................................................................................................................
.....................................................................................................................................................................

**៥. ទីតាំងដែលកំពុងទទួលរងឥទ្ធិពល និងទីតាំងដែលទំនងនឹងរងឥទ្ធិពលបន្ថែម**

| ឈ្មោះភូមិដែលកំពុងទទួលរងគ្រោះ | ប្រជាជនប៉ះពាល់ | | | ក្រុមងាយរងគ្រោះ | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រួសារ | នាក់ | | គ្រួសារ | នាក់ | | ស្ត្រី ( នាក់ ) | | កុមារ( នាក់ ) | | | | | | ជរា( នាក់ ) 65ឆ្នាំឡើង | | ជនពិការ ( នាក់ ) | | កុមារពិការ ( នាក់ ) | | មានជម្ងឺរ៉ាំរ៉ៃ HIV-AIDS, របេង ( នាក់ ) | | គ្រួសារក្រីក្រ | | | ស្ត្រីមេគ្រួសារ |
| | | | | | | | មានគភ៌ | បំបៅកូន | 0-5 ឆ្នាំ | | 6-14 ឆ្នាំ | | 15-18ឆ្នាំ | | | | | | | | | | គ្រួសារ | នាក់ | | |
| | | ស្រី | ប្រុស | | ស្រី | ប្រុស | | | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | | ស្រី | ប្រុស | |
| | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | | | |

ការបញ្ជាក់បន្ថែម(បើមាន) ៖......................................................................................................................................................................................................

.............................................................................................................................................................................................................................

.............................................................................................................................................................................................................................

## ៦. មនុស្សរងគ្រោះថ្នាក់ (ស្លាប់,របួស,បាត់ខ្លួន)

| ល.រ. | ឈ្មោះភូមិ | ស្លាប់,របួស,បាត់ខ្លួន | ឈ្មោះជនរងគ្រោះ | ភេទ | អាយុ | ថ្ងៃ.ខែ.ឆ្នាំ ទទួលរងគ្រោះ | មូលហេតុ |
|---|---|---|---|---|---|---|---|
| 1 | | ☐ ស្លាប់ ☐ របួស ☐ បាត់ខ្លួន | | | | | |
| 2 | | ☐ ស្លាប់ ☐ របួស ☐ បាត់ខ្លួន | | | | | |
| 3 | | ☐ ស្លាប់ ☐ របួស ☐ បាត់ខ្លួន | | | | | |
| 4 | | ☐ ស្លាប់ ☐ របួស ☐ បាត់ខ្លួន | | | | | |

ការបញ្ជាក់បន្ថែម (បើមាន) ៖......................................................................................................................................................................................................

.............................................................................................................................................................................................................................

.............................................................................................................................................................................................................................

## ៧. ជំលៀស

| ឈ្មោះភូមិដែលបានជំលៀសចេញ | ចំនួនគ្រួសារ | ចំនួនមនុស្ស | ទៅកាន់ទីសុវត្ថិភាព | | | ឈ្មោះទីតាំងសុវត្ថិភាព | នៅតាមផ្ទះសាច់ញាតិ | | |
|---|---|---|---|---|---|---|---|---|---|
| | | | គ្រួសារ | មនុស្ស | | | គ្រួសារ | មនុស្ស | |
| | | | | ស្រី | ប្រុស | | | ស្រី | ប្រុស |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ការបញ្ជាក់បន្ថែមដូចជា ប្រជាជនកំពុងនៅបន្តជំលៀសមកជាហូរហែរ (បើមាន) ៖...............................................................................................

...............................................................................................

...............................................................................................

...............................................................................................

.

## ៧.១. ស្ថានភាព/សេចក្តីត្រូវការនៃប្រជាជនទីសុវត្ថិភាព

| ១) ឈ្មោះទីតាំងសុវត្ថិភាព | ចំនួនប្រជាជនរងគ្រោះ | | | ចំនួនគ្រួសារដែលកំពុងមានការប្រឈម/ខ្វះខាតសំរាប់ការរស់នៅប្រចាំថ្ងៃ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | គ្រួសារ | មនុស្ស | | ជម្រក | ទឹកស្អាត | ស្បៀង | សម្លៀកបំពាក់ | សម្ភារៈដាំស្ល | ធុងដាក់ទឹក | បង្គន់ | អនាម័យ |
| | | ស្រី | ប្រុស | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| ២) ឈ្មោះទីតាំងក្រៅ ទីសុវត្ថិភាព | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

ការបញ្ជាក់បន្ថែម(បើមាន) ៖...............................................................................................

...............................................................................................

...............................................................................................

...............................................................................................

## ៨. ឥទ្ធិពល និង ការខូចខាត

### ៨.១. ផ្ទះ, និងសំណង់សាធារណៈ

| ឈ្មោះភូមិ | ចំនួនផ្ទះប៉ះពាល់ (ខ្នង) | | | ចំនួនមណ្ឌលសុខភាព ប៉ះពាល់(កន្លែង) | | | ចំនួនសាលារៀន ប៉ះពាល់ (កន្លែង) | | | ចំនួនវត្តប៉ះពាល់ (កន្លែង) | | | សាលាឃុំ/សង្កាត់ (កន្លែង) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | តិចតួច | មធ្យម | ធ្ងន់ធ្ងរ | តិចតួច | មធ្យម | ធ្ងន់ធ្ងរ | តិចតួច | មធ្យម | ធ្ងន់ធ្ងរ | តិចតួច | មធ្យម | ធ្ងន់ធ្ងរ | តិចតួច | មធ្យម | ធ្ងន់ធ្ងរ |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

ការបញ្ជាក់បន្ថែមករណីមានសំណង់អគារដែលប៉ះពាល់ធ្ងន់ធ្ងរមិនអាចដំណើរការនិងមិនអាចចូលទៅបាន(បើមាន) ៖ ....................................................................................................

....................................................................................................

....................................................................................................

....................................................................................................

### ៨.២. ទ្រព្យសម្បត្តិពិសេស និងមានតម្លៃ

| រាយឈ្មោះ | ឯកតា | ចំនួន/បរិមាណ | | មូលហេតុ |
|---|---|---|---|---|
| | | បាត់បង់ | ខូចខាត | |
| | | | | |
| | | | | |
| | | | | |
